ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អអក

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ០៧២.សណ១៧អអក

ភ្នំពេញ, ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់លោកស្រី អាន់ សំឡាន សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង

អាជ្ញាធរអគ្គិសនីកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណលេខ ១០៦ អ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ ឲ្យលោកស្រី អាន់ សំឡាន សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង ក្នុងអាណត្តិមុនគឺ ៥ឆ្នាំ ។ ក្នុងអាណត្តិមុននេះលោកស្រី អាន់ សំឡាន បានធ្វើការកែលម្អមធ្យោបាយធ្វើសេវាកម្មបានមួយចំនួន ហើយត្រូវបន្តកែលម្អទៀតនៅឆ្នាំបន្តបន្ទាប់ ។ ដោយយល់ឃើញថា លោកស្រី អាន់ សំឡាន មានឆន្ទៈក្នុងការកែលម្អ និងបង្កើនប្រសិទ្ធភាពអាជីវកម្មរបស់ខ្លួនបន្ថែមទៀត អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី អាន់ សំឡាន ដោយផ្តល់អាណត្តិអាជ្ញាបណ្ណ ចំនួន ០៧(ប្រាំពីរ)ឆ្នាំបន្តទៀត ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាណត្តិអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជន មានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារនៃសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ...........................................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោកស្រី អាន់ សំឡាន អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ** " ។/.

អាជ្ញាធរអគ្គិសនីកម្ពុជា

ប្រធាន

បណ្ឌិត.ទិ នរិន្ទ

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

សេចក្តីព្រាង

អាជ្ញាធរអគ្គិសនីកម្ពុជា

ELECTRICITY AUTHORITY OF CAMBODIA

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីសម្រេចកែសម្រួលលើកទី៣ លើឯកសារអាជ្ញាបណ្ណលេខ ១០៦ ឯអ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៤ សម្រាប់លោកស្រី អាន់ សំឡាន ធ្វើសេវាកម្មអគ្គិសនីនៅឃុំកោះស្តេច ស្រុកគិរីសាគរ ខេត្តកោះកុង

## សម្រាប់ការបន្តអាណត្តិអាជ្ញាបណ្ណ

# DECISION ON THE THIRD REVISION

OF THE LICENSE DOCUMENT No. 106 LD DATED NOVEMBER 19, 2004
FOR MRS. ANN SAMLAN FOR PROVIDING ELECTRIC POWER
SERVICE AT KHUM KOH SDECH, KIRISAKOR DISTRICT,
KOH KONG PROVINCE

## FOR RENEWAL OF TERM OF LICENSE

ថ្ងៃទី... ខែ...... ឆ្នាំ២០១៧

... ... ..., 2017